59/7

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី
លេខ : ០៦
ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៥១ "ផ"
ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤។

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

១-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោកស្រី ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**អ្នកស្រី [redacted] រីរីទី (ចុងបណ្តឹងសាទុក្ខ) អាយុ ៤២ឆ្នាំ ជាតិខ្មែរ មុខរបរ-រកស៊ី ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១២៣AE០ ផ្លូវលេខ ២២៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈ**អ្នកស្រី [redacted] សុភាព (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ-មន្ត្រីរាជការ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៧៣E០ ផ្លូវ ២០០៤ ក្រុមទី ១៤ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

៣៤០



Scanned with CamScanner

អំពីវិវាទៈ-ប្តឹងទារប្រាក់

## អំពីអង្គហេតុនិង ចំណុចវិវាទៈ

ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ

១-សាលក្រមទាមទារដោយដើមចោទៈ

ក/សុំរំលាយកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

ខ/សុំអោយឈ្មោះ [redacted] សុភាព បង់ប្រាក់ចំនួន ១.២០០.០០០រៀល( មួយលានពីរសែនរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

គ/ទាមទារថ្លៃចាក់ដី ធ្វើដំបូល និង ថ្លៃទទឹក ៩១.៦៣៥ដុល្លា( ប្រាំបួនម៉ឺនមួយពាន់ប្រាំមួយរយសាមសិបប្រាំដុល្លាអាមេរិក) ។

ឃ/ទាមទារប្រាក់កក់ចំនួន ៤.៨០០ដុល្លា( បួនពាន់ប្រាំបីរយដុល្លាអាមេរិក) គុណ ៣ មកកូនក្តីខ្លួនឈ្មោះ [redacted] វីរីនី តាមកិច្ចសន្យាចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

ង/សងជម្ងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ រួមទាំងចំណាយសេវាមេធាវីជាប្រាក់ចំនួន ១០០.០០០ដុល្លា( ដប់ម៉ឺនដុល្លាអាមេរិក) ។

ច/សុំអោយតុលាការប្រកាសថា សាលក្រមនេះអនុវត្តជាបណ្តោះអាសន្នបាន ។

ឆ/ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៤ក្រ២(ណ) ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេច :**

១-រំលាយកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ រវាងឈ្មោះ កែវ សុភាព ជាភាគីម្ចាស់ផ្ទះ និង ឈ្មោះ [redacted] វីរីនី ជាភាគីអ្នកជួលផ្ទះ ចោលជាអសារបង់ ។

២-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុភាព ផ្តល់សំណងអោយដើមចោទ [redacted] វីរីនី ដូចខាងក្រោមៈ

ក-សងថ្លៃចាក់ដី និង ជួសជុលផ្ទះចំនួន ៥៦.០៧០ដុល្លា( ប្រាំម៉ឺនប្រាំមួយពាន់សូន្យរយចិតសិបដុល្លាអាមេរិក) ។

ខ-សងថ្លៃខាតបង់អាជីវកម្ម, ថ្លៃប្រាក់កក់ និង សេវាកម្មមេធាវី សរុបចំនួន ១២ម៉ឺនដុល្លា(ដប់ពីរម៉ឺនដុល្លាអាមេរិក) ការទាមទារប្រាក់លើសពីនេះ ត្រូវច្រានចោល ។

គ-ច្រានចោលការទាមទារសុំអនុវត្តបណ្តោះអាសន្នរបស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទ ។

៣-ប្រគល់សំភារៈអោយដើមចោទ តាមរបាយការណ៍រៀបចំទីតាំងសម្រាប់ប្រកបអាជីវកម្ម ចុះថ្ងៃទី

១២ ខែ មីនា ឆ្នាំ ២០១២ របស់ភាគីដើមចោទ តាមចំណុចដូចខាងក្រោមៈ-

-សំភារៈសំអាង និង សំភារៈកាត់សក់បុរស-នារី( ក្នុងចំណុចគ) ។

-សំភារៈផលិតផលសំអាង( ក្នុងចំណុចឃ) ។

-សំភារៈលក់អាហារពេលយប់( ក្នុងចំណុចង) និង សំភារៈផ្សេងៗ( ក្នុងចំណុចច) ។

៤-ប្រគល់សំភារៈអោយចុងចម្លើយ ដែលដើមចោទបានបំពាក់ជាប់ផ្ទះ តាមរបាយការណ៍រៀបចំទីតាំងសម្រាប់ប្រកបអាជីវកម្ម ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ របស់ភាគីដើមចោទ តាមចំណុចដូចខាងក្រោម :-

-សំភារៈដំបូល. កញ្ចក់ឆ្លុះ និង តុកាត់សក់បុរសនារី( ក្នុងចំណុចក) ។

-ការចាក់ដីបំពេញលើទីតាំង ផ្លូវ សំណង់ខាងក្នុង( ក្នុងចំណុច ខ) ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៦-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] សុភាព ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ១៨៨ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១២ ត្រង់ចំណុចទី ២. ទី ៥ នៃសេចក្តីសំរេច ។*

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៤"ក្រប"ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ សំរេចៈ

១-ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ កែវ សុភាព ចោលជាអសារបង់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៤ក្រ២"ណ" ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីឈ្មោះ [redacted] សុភាព អ្នកចាញ់ក្តី ។

៤-សាលដីកានេះ ទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ ០១ខែ គិតពីថ្ងៃទទួលការជូនដំណឹងពីសាលដីកានេះ ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] សុភាព ប្តឹងសាទុក្ខតាមបណ្តឹងលេខ ០៩ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។*

ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគីៈ

ឈ្មោះ [redacted] សុភាព ធ្វើសេចក្តីថ្លែងការណ៍ថា ៈតុលាការថ្នាក់ក្រោមសំរេចមិនត្រូវ ព្រោះខ្លួនជួលតែសំបកផ្ទះអោយដើមចោទប៉ុណ្ណោះ ដូចមានមេភូមិជាសាក្សី តែដើមចោទមិនគោរពកិច្ចសន្យា និង បង្កការលំបាកអោយខ្លួន និង មិនបានបង់ថ្លៃឈ្នួលផ្ទះអោយខ្លួននៅខែដំបូង តែខែបន្ទាប់គាត់បង់អោយប្រអប់ខែ ។ ពេល



Scanned with
CamScanner

បេរ្លូមិបហៅគាត់មកជួប គាត់ថា គាត់មិនបង់ទេខែ ១០នេះ ។ ក្រោយមកនៅខែមករា ឆ្នាំ ២០១២ គាត់លែងបង់ថ្លៃឈ្នួលផ្ទះអោយខ្លួនរហូតមក មិនតែប៉ុណ្ណោះគាត់បានសុំជីការព្យាការពារទៀតផង ។ នៅក្នុងកិច្ចសន្យាមិនមានប្រការណាមួយចែងអោយគាត់ចាក់ដីរឺធ្វើជំបូលទេ ហើយជាក់ស្តែងក៏ពុំមានការចាក់ដី និង ជួសជុលដូចការលើកឡើងរបស់ដើមចោទដែរ ព្រោះផ្ទះខ្លួនធ្វើហើយស្រាប់ ។ ចំពោះការអះអាងរបស់ដើមចោទអំពីការចាក់ដី និង ជួសជុលផ្ទះ គឺពុំពិតទេ ។

អគ្គិសនីខ្លួនជាអ្នកត ពេលដើមចោទមកជួល ។ ចំពោះការផ្តាច់ភ្លើង គឺខ្លួនអោយមន្ត្រីអគ្គិសនីផ្តាច់ ព្រោះដើមចោទមិនព្រមបង់ថ្លៃឈ្នួលផ្ទះអោយខ្លួន និង មិនព្រមចូលខ្លួនទៅដោះស្រាយ ។

ក្រឡាបញ្ជីអានសារណាតបរបស់ដើមចោទ

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីខ្លួនអះអាងថា ពុំដែលមានការរាក់ខានក្នុងការបង់ប្រាក់ឈ្នួលតាំងពីខែដំបូងដូចការលើកឡើងរបស់ចុងចម្លើយទេ ។ ប្រាក់ឈ្នួលចុងក្រោយបំផុត គឺចុងឆ្នាំ ២០១១ ។ បើកូនក្តីខ្លួនមិនបានបង់តាំងពីខែដំបូង ម្តេចចុងចម្លើយមិនប្តឹងសុំរំលាយកិច្ចសន្យានេះទៅ ។ ចំពោះការចាក់ដី និង ជួសជុលសាងសង់ គឺដើម្បីអោយអាជីវកម្មមានដំណើរការល្អដែលអស់ទឹកប្រាក់ចំនួន ៩១.៦៣៥ដុល្លារអាមេរិក ។ ការផ្តាច់ទឹកភ្លើងរបស់ចុងចម្លើយធ្វើអោយកូនក្តីខ្លួនត្រូវខាតប្រាក់ចំណូលក្នុង១ថ្ងៃ ១.២០០.០០០រៀល ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា ៖ នៅសាលាឧទ្ធរណ៍ពុំឃើញមានលិខិតតំណាងអាណត្តិរបស់លោកមេធាវី [redacted] ទេ ខ្លួនសុំជំទាស់ ។ ពេលជូនដំណឹងអំពីសាលដីកាកំបាំងមុខ គឺសាលដីកានោះពុំមានចុះហត្ថលេខា បោះត្រាទេ ។

កូនក្តីខ្លួនបានចុះកិច្ចសន្យាជួលផ្ទះអោយ [redacted] វីរៈធី ដោយមានអាជ្ញាធរឃុំដឹងឮ ។ [redacted] វីរៈធី មិនបានបង់ប្រាក់ថ្លៃឈ្នួលផ្ទះតាំងពីខែដំបូងមកម្ល៉េះ ហើយការដែលកូនក្តីខ្លួនមិនប្តឹងសុំរំលាយកិច្ចសន្យា គឺមកពីមានការសុំពន្យាថា ពេលនេះ ពេលនោះរហូតមក ។ ខែ ០១-២០១០ ដើមចោទបានប្តឹងឃាត់ផ្ទះកូនក្តីខ្លួន ។

កិច្ចសន្យារបស់គូភាគីពុំមានចែងអោយដើមចោទចាក់ដី រឺ ជួសជុលផ្ទះទេ គឺកូនក្តីខ្លួនជួលអោយតែសំបកផ្ទះប៉ុណ្ណោះ ដូច្នេះ ការចាក់ដី និង ការជួសជុលផ្ទះរបស់ដើមចោទ គឺដើមចោទជាអ្នកទទួលខុសត្រូវ ។

សំណូមពរ ៖សុំបដិសេធចោលសាលដីកាសាលាឧទ្ធរណ៍ និង សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីខ្លួនបានជួលផ្ទះពីឈ្មោះ [redacted] សុភាព រយៈពេល ៥ឆ្នាំ តាមកិច្ចសន្យា ចុះថ្ងៃទី ០១-១០-២០១០ ដោយបានចាក់ដី និង ជួសជុលសាងសង់ គឺដើម្បីអោយអាជីវកម្មមានដំណើរការល្អដែលអស់ទឹកប្រាក់ចំនួន ៩១.៦៣៥ ដុល្លារអាមេរិក ។ ក្រោយពីជួលបានតែជាង១ឆ្នាំ ឈ្មោះ [redacted] សុភាព បានផ្តាច់ទឹកភ្លើង ធ្វើអោយកូនក្តីខ្លួនត្រូវខាតប្រាក់ចំណូលក្នុង១ថ្ងៃ ១.២០០.០០០រៀល ។

នៅចំណុចទី ៥-២ ចែងថា ភាគី "ក" ពុំអាចបញ្ឈប់ការជួលមុនកំណត់ទេ។

នៅចំណុចទី ៧-៣ ចែងថា បើភាគី "ខ" មិនបង់ប្រាក់ឈ្នួលក្នុងរយៈពេល ៣០ថ្ងៃ ភាគី "ក" អាចសុំផ្តាក កូនក្តីខ្លួនបានបង់ប្រាក់កក់១២ខែមុនស្មើនឹង៤.៨០០ដុល្លា ដើម្បីធានាក្នុងការជួល។ ដូច្នេះ ចុងចម្លើយអាចកាត់យកពីប្រាក់កក់នេះបាន រឺប្តឹងសុំរំលាយកិច្ចសន្យានេះវិញ។

ដោយមើលឃើញទីតាំងជួលនេះល្អ មានចំណូលច្រើន ទើបកូនក្តីខ្លួនចំណាយប្រាក់ច្រើនសន្ធឹកសន្ធាប់ ដើម្បីចាក់ដី និង ជួសជុលផ្ទះអោយបានស្អាត។

**សំណូមពរ៖** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ, អំណានសារណាតប របស់ដើមចោទ និង សេចក្តីថ្លែងការណ៍របស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៩ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ របស់ចុងចម្លើយឈ្មោះ [redacted] សុភាព ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលបង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុភាព ផ្តល់សំណងទៅអោយដើមចោទឈ្មោះ [redacted] វិរិទ្ធី នូវថ្លៃចាក់ដី និង ជួសជុលផ្ទះជួលចំនួន ៥៦.០៧០ដុល្លា និង សងថ្លៃខាតបង់អាជីវកម្ម, ថ្លៃប្រាក់កក់, សេវាកម្មមេធាវី សរុបចំនួន ១២០.០០០ដុល្លាអាមេរិក នោះ ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ពីព្រោះ :-

+សំអាងហេតុរបស់សាលាដំបូង ដែលថា ដើមចោទឈ្មោះ [redacted] វិរិទ្ធី បានបង់ប្រាក់ថ្លៃឈ្នួលផ្ទះជាប្រចាំហែរក្នុងមួយខែ ៤០០ដុល្លា ដូចមានរបាយការណ៍ស្តីពីការបង់ប្រាក់ប្រចាំខែ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ដាក់សំអាងនោះ គឺជាការភ័ន្តច្រឡំ ព្រោះថា ក្នុងរបាយការណ៍នេះ បានសរសេរថា នៅខែ ធ្នូ ឆ្នាំ ២០១០ ដល់ខែ មករា ឆ្នាំ ២០១២ មិនទាន់បង់ប្រាក់។ (១៧២)

+ការដែលសាលាដំបូងសំអាងថា ចុងចម្លើយឈ្មោះ [redacted] សុភាព បានទទួលប្រាក់ថ្លៃឈ្នួលផ្ទះពីដើមចោទ

ទៅខែដំបូង ខែ ធ្នូ ឆ្នាំ ២០១០ ដែលចុងចម្លើយបានអះអាងថា មិនទាន់បង់ថ្លៃឈ្នួលផ្ទះសម្រាប់ខែនេះនោះ សាលាដំបូង និង សាលាឧទ្ធរណ៍ ពុំមានសំអាងហេតុច្បាស់លាស់អំពីការប្រគល់ប្រាក់នេះទេ ហើយចំពោះការបង់ប្រាក់ថ្លៃឈ្នួលផ្ទះសម្រាប់ខែ មករា និង ខែ កុម្ភៈ ឆ្នាំ ២០១២ ក៏គ្មានសំអាងហេតុបញ្ជាក់ដែរ។ លើសពីនេះ ចុងចម្លើយបានដាក់ឯកសារភស្តុតាងមួយចំនួនស្តីពីការមិនបង់ប្រាក់ថ្លៃជួលផ្ទះនៅតុលាការកំពូល តុលាការកំពូលពិចារណាថា គប្បីទទួលយកមកពិនិត្យ ទោះបីជាចុងចម្លើយទើបនឹងដាក់ក៏ដោយ ក៏ឯកសារនេះ តុលាការអាចពិនិត្យភ្លាមៗបាន និង មិននាំអោយមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ដែលមានកំណត់ក្នុងមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ។

+ចំណុចវិវាទរវាងគូភាគី ការមិនបង់ប្រាក់ថ្លៃឈ្នួលផ្ទះ និង ការផ្តាច់ចរន្តអគ្គិសនី ដែលបង្កឡើងដោយចុងចម្លើយ ដោយផ្អែកតាមខ្លឹមសារ នៃកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាពិសេសប្រការ ៧-៣។ ប៉ុន្តែ តុលាការអង្គសេចក្តីមិនមានការពិចារណានៅឡើយទេ។ ម្យ៉ាងទៀត តុលាការអង្គសេចក្តីក៏មិនមានការពិចារណាអំពីកាតព្វកិច្ចក្នុងការទទួលខុសត្រូវចំពោះការចាក់ដី និង ការជួសជុលផ្ទះជួល សេវាមេធាវី ព្រមទាំងទំហំនៃការទាមទាររបស់ដើមចោទ ស្របតាមកិច្ចសន្យារបស់គូភាគី និង ច្បាប់ជាធរមាន នៅឡើយដែរ។

-យល់ឃើញថា នាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ ដើមចោទមិនបានចូលរួមតាមការកោះហៅត្រឹមត្រូវរបស់តុលាការកំពូលទេ ប៉ុន្តែ បានដាក់សារណា និង មានមេធាវីចូលរួមហើយ ដូច្នេះ តុលាការកំពូលអាចជំនុំជំរះបាន។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៤"ក្រប" ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមគតិច្បាប់ទេ។

**ហេតុដូចនេះ**

**ស ម្រេ ច**

**ទ និ ច្ឆ័ យ សេ ច ក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ របស់ចុងចម្លើយឈ្មោះ [redacted] ស្មុភាព។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ៣៤"ក្រប" ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ០៦ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មី។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]

បានឃើញ
ភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

៣៨៦



386

Scanned with CamScanner